រាជរដ្ឋាភិបាល
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia
លេខ...២៣៣៦/២៤.....ក.អ.ក.

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
*Nation- Religion- King*

ថ្ងៃ...ពុធ.......១២រោច...ខែ...កត្តិក.....ឆ្នាំ...រោង ឆស័ក...ព.ស ២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី...២៧........ខែ...វិច្ឆិកា....ឆ្នាំ ២០២៤

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគកម្ពុជា
## ( ប្រព័ន្ធ cdcIPM )

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក.) មានកិត្តិយសសូមជម្រាបជូនសាធារណជន វិនិយោគិនជាតិ-អន្តរជាតិ និងបណ្តាញសារព័ត៌មានទាំងអស់ឱ្យបានជ្រាបថា៖ ក.អ.ក. បាននិងកំពុងខិតខំប្រឹងប្រែងទាក់ទាញវិនិយោគិនឱ្យមកបណ្តាក់ទុននៅកម្ពុជា ដើម្បីចូលរួមបង្កើតការងារជូនបងប្អូនប្រជាពលរដ្ឋ ជំរុញកំណើនសេដ្ឋកិច្ចជាតិ ឆ្ពោះទៅសម្រេចឱ្យបាននូវចក្ខុវិស័យ កម្ពុជាជាប្រទេសមានចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

ក្នុងគោលបំណងជំរុញការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ចូលរួមគាំទ្រការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងដោយមានការចង្អុលបង្ហាញផ្ទាល់ពី ឯកឧត្តម **ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា** ក.អ.ក. បានរៀបចំប្រព័ន្ធគ្រប់គ្រងគម្រោងវិនិយោគកម្ពុជា (CDC Investment Project Management) ហៅកាត់ថា **"ប្រព័ន្ធ cdcIPM"** ។ ប្រព័ន្ធ cdcIPM នេះផ្តល់លទ្ធភាពឱ្យវិនិយោគិនដាក់ពាក្យដោយផ្ទាល់ពីគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ដើម្បីសម្រួលកិច្ចវិនិយោគឱ្យកាន់តែមានភាពងាយស្រួល កាត់បន្ថយពេលវេលា ធានាបាននូវតម្លាភាព សុក្រឹតភាព និងប្រសិទ្ធភាព ព្រមទាំងចូលរួមកសាងសេដ្ឋកិច្ច និងសង្គមឌីជីថល និងរដ្ឋាភិបាលឌីជីថលនៅកម្ពុជា។

ក្រោយពីបានប្រើប្រាស់សាកល្បងផ្ទៃក្នុងដោយជោគជ័យ អស់រយៈពេលប្រមាណជាងមួយត្រីមាសកន្លងទៅលើការចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ក.អ.ក. បានសម្រេច **ដាក់ឱ្យប្រើប្រាស់ជាផ្លូវការ** នូវ **ប្រព័ន្ធ cdcIPM** ដើម្បីជាប្រយោជន៍ដល់វិនិយោគិន ដែលមានបំណងចង់ដាក់ពាក្យស្នើសុំចុះបញ្ជីគម្រោងវិនិយោគរបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

អាស្រ័យហេតុនេះ សូមសាធារណជន វិនិយោគិនជាតិ-អន្តរជាតិ និងបណ្តាញសារព័ត៌មានទាំងអស់មេត្តាជ្រាប និងចូលរួមផ្សព្វផ្សាយឱ្យបានទូលំទូលាយ៕

Download on the App Store | GET IT ON Google Play | VISIT Online

cdc IPM

ipm.cdc.gov.kh

**អគ្គលេខាធិការដ្ឋាន**
**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**



cdcIPM

# Investment Project Management

## 3 ways to access cdcIPM

Download on the App Store

GET IT ON Google Play

VISIT Online

# Key Features

- Available Cross Platform https://
- Automated Fee Determination
- Online Payment
- Anywhere, Anytime
- Preliminary AI Support
- Email/Telegram/In-App Notification
- Application Status Tracking
- Fully Generated Digital Documents
- Working Progress Dashboard
- Privacy Protection
- Security Protection
- Flexible Workflow



# STATUS TRACKING

Investor

Decision Maker













# DIGITAL DOCUMENTS



# E-Signature



Attachment (Optional)
Select
Must be in PDF, PNG, JPG, JPEG format and file size must be ≤10Mb
Comments Preliminary Review (2/13) *
Tap here to sign
Back
Save
Submit




cdc IPM Investment Project Management
Home
2. Preliminary Review
Confirmation
Attachment (Optional)
Select
Must be in PDF, PNG, JPG, JPEG format and file size must be ≤10Mb
Comments Preliminary Review (2/13) *
Back
Save
Submit




• Communication History

# cdcIPM Assistant







# AI Trained for Investment Related Response

